# <u>ចិនប៉េកាំងនិយាយឲ្យល្អស្តាប់</u>

*គណៈបក្សសង្គ្រោះជាតិបានប្រកាសជាផ្លូវការថាមិនព្រមទទួលយកលទ្ធផលបោះឆ្នោត កាលពី ២៨ កក្កដា ដែល គ ជ ប ប្រកាសជាបណ្តោះអាសន្ន ដោយគ្មានគណៈកម្មការអព្យាក្រិត្យ ឯករាជ ធ្វើការអង្កេតពីការមិនប្រក្រតី និង លួចបន្លំ លទ្ធផល។ ហេតុនេះ បានសេចក្តីថា គណៈបក្សសង្គ្រោះជាតិគ្មានគំនិតចរចាជាមួយគណៈបក្សប្រជាជនកម្ពុជា ក្នុងការបង្កើតរដ្ឋសភាថ្មី និងរាជរដ្ឋាភិបាល។*

*ក៏ប៉ុន្តែ លោក វ៉ាង យី រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណៈរដ្ឋប្រជាមានិតចិន បានមកធ្វើទស្សនៈកិច្ចនៅប្រទេសខ្មែរកាលពីទី ២០ ខែ ៨ នេះបានជួបជាមួយលោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស ហើយបានប្រកាសថាប្រទេសចិនគាំទ្រការចរចាគ្នាដោយសន្តិភាព ក្នុងការបង្កើតរដ្ឋសភាថ្មី និងរាជរដ្ឋាភិបាល ឲ្យបានឆាប់បំផុត។ ប៉ុន្តែចិនបានទទួលស្គាល់ជ័យជំនះរបស់ គណៈបក្សប្រជាជនកម្ពុជាទៅហើយ នេះគឺផ្ទុយស្រឡះពីការសំរេចចិត្តរបស់ គណៈបក្សសង្គ្រោះជាតិ។*

*លោក វ៉ាង យី បានបញ្ជាក់ថែមទៀតថា កម្ពុជា និងចិន គឺជាអ្នកជិតខាងល្អ មិត្តល្អ និងជាបងប្អូនល្អ ហើយយើងបន្តជួបពិភាក្សាគ្នាឲ្យបានញឹកញាប់។ នេះប្រហែលជាលោកវ៉ាងយី ភ្លេចពីចិនដែលគាំទ្រខ្មែរក្រហម ឲ្យសំឡាប់ប្រជាពលរដ្ឋខ្មែរអស់ជាង ២ លាននាក់ ហើយប្រទេសខ្មែរហិនហោច គ្រប់បែបយ៉ាង ទាល់តែយួនមកត្រួតត្រា។*

*នៅពេលពួកខ្មែរក្រហមកាន់អំណាច ក៏ចិនឆ្លៀតយកចំណេញពីប្រទេសខ្មែរដែរ។ ដូចសព្វថ្ងៃនេះ ចិនឆ្លៀតយកចំណេញទៀតពីពួកហុនសែនដែលកាន់អំណាច ដូចជារ៉ែគ្រប់បែបយ៉ាងព្រមទាំងឲ្យខ្មែរខ្ចីលុយ សង់ផ្លូវ ឲ្យចិនប្រើដឹករ៉ែ។*

*មុននឹង លោក វ៉ាង យីប្រកាសយ៉ាងនេះ គួរតែលោកជួបជាមួយ គណៈបក្សសង្គ្រោះជាតិ សិន តើមានគំនិតយ៉ាងដូចម្តេច។*

លោក វ៉ាង យី ប្រកាសយ៉ាងនេះ គឺដើម្បីធ្វើការកៀបសង្កត់ទៅលើអ្នកដឹកនាំ គណៈបក្សសង្គ្រោះជាតិ ហើយ ឲ្យមតិមហាជន និង ប្រជាពលរដ្ឋខ្មែរ យល់ច្រឡំ នឹង លែងទុកចិត្ត និង សង្ស័យថា គណៈបក្សសង្គ្រោះជាតិនឹងធ្វើទៅតាមការស្នើរបស់ចិន។

ជាមួយពេលនេះ ពួកលាក់មុខ ឬ លាក់ឈ្មោះ ដែលគាំទ្រ គណៈបក្សប្រជាជនកម្ពុជា ឲ្យយួនត្រួតស្រុក ក៏នាំគ្នាបំពងសំឡេង ដោយគ្មានមូលហេតុច្បាស់លាស់ ថា គណៈបក្សសង្គ្រោះជាតិ កំពុងចរចាជាមួយ គណៈបក្សប្រជាជនកម្ពុជា ដើម្បីចែកអំណាចគ្នា ដោយក្បត់នឹងឆន្ទៈប្រជាពលរដ្ឋ ដែលគាំទ្រ គណៈបក្សសង្គ្រោះជាតិ។

គណៈបក្សសង្គ្រោះជាតិប្រកាសគ្រប់ពេលទាំងអស់ មិនព្រមទទួលស្គាល់លទ្ធផលបោះឆ្នោត កាលពីថ្ងៃ ២៨ កក្កដា ដោយគ្មានគណៈកម្មការអព្យាក្រិត្យ ឯករាជ ធ្វើការអង្កេតពីការមិនប្រក្រតី និង លួចបន្លំ លទ្ធផល នោះទេ។ ហើយគណៈបក្សសង្គ្រោះជាតិមិនព្រមចរចាអ្វីទាំងអស់ជាមួយ គណៈបក្សប្រជាជនកម្ពុជា ដែលជាចោរលួចលទ្ធផលឆ្នោត ក្នុងការបង្កើត រាជរដ្ឋាភិបាលនោះទេ។

លិម គិម យ៉ា

តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិនៅខេត្តកំពង់ធំ